# កំរិតធាតុ ហ្វ័រម៉ាដេហៃដ៍ នៅក្នុងផ្ទះសណ្ដោងដែល FEMA បានផ្គត់ផ្គង់

## ការរកឃើញជាដំបូងចេញពី មជ្ឈមណ្ឌលសំរាប់ទប់ស្កាត់ និងបង្ការជំងឺ

### គោលបំណង

ព្រឹត្តបត្រនេះនឹងប្រាប់អ្នកនូវអ្វីៗដែលអ្នកស្រាវជ្រាវបានរកឃើញ នៅក្នុងការពិនិត្យសាកនៅពេលថ្មីៗនេះ អំពីខ្យល់នៅខាងក្នុងផ្ទះសណ្ដោងចរ (Travel Trailer) និងផ្ទះចល័ត (Mobile Home) ដែលបានផ្គត់ផ្គង់ដោយ ភ្នាក់ងាររដ្ឋបាលសហព័ន្ធផ្នែកការចាត់ចែងអាសន្ន (Federal Emergency Management Agency - FEMA) នៅក្នុងសហគមន៍របស់អ្នក ។ វាក៏នឹងផ្ដល់ឲ្យអ្នកនូវព័ត៌មានដើម្បីការពារសុខភាពរបស់អ្នក និងព័ត៌មានអំពីជំនួយក្នុងការរកទីលំនៅជាអចិន្ត្រៃយ៍ផងដែរ ។

### ប្រវត្តិ

នៅក្នុងខែធ្នូឆ្នាំ 2007 និងខែមករាឆ្នាំ 2008 មជ្ឈមណ្ឌលសំរាប់ទប់ស្កាត់ និងបង្ការជំងឺ (Centers for Disease Control and Prevention - CDC) បានពិនិត្យសាក ដើម្បីរកឲ្យដឹងអំពីកំរិតនៃធាតុ ហ្វ័រម៉ាដេហៃដ៍ (formaldehyde) គឺធាតុឧស្ម័នឥតពណ៌ដែលរមាស់ នៅក្នុងខ្យល់ខាងក្នុងផ្ទះសណ្ដោងចរ និងផ្ទះចល័ត ដែលបានផ្គត់ផ្គង់ដោយ FEMA ។ CDC បានវិភាគទិន្នន័យចេញពីការពិនិត្យសាក ហើយបានរកឃើញថាវាប៉ះពាល់ដល់សុខភាពរបស់ប្រជាជន ដែលកំពុងរស់នៅក្នុងផ្ទះសណ្ដោង និងផ្ទះចល័ត ដែលបានផ្គត់ផ្គង់ដោយ FEMA ។ **ទាំងនេះគឺការរកឃើញជាដំបូង ហើយវាក៏មិនមែនជាចុងក្រោយទេ ។** CDC នឹងចែកចាយព័ត៌មានទៀត នៅប៉ុន្មានអាទិត្យខាងមុខនេះ ។

### តើ CDC បានរកឃើញអ្វី?

- នៅក្នុងផ្ទះសណ្ដោង ផ្ទះចល័តជាច្រើន ព្រមទាំងផ្ទះខ្លះក្នុងឧទ្យានដែលបានពិនិត្យសាក បានរកឃើញកំរិតធាតុហ្វ័រម៉ាដេហៃដ៍កើនឡើង ។ កំរិតគឺខ្ពស់ជាងធម្មតានៅក្នុងខ្យល់ខាងក្នុងផ្ទះភាគច្រើននៅក្នុងសហរដ្ឋអាមេរិក ។
- កំរិតមធ្យមនៃធាតុហ្វ័រម៉ាដេហៃដ៍ នៅក្នុងផ្ទះសណ្ដោងចរ និងផ្ទះចល័ត គឺមានប្រហែល 77 ភាគក្នុងមួយកោដិ (ppb) ។ ការដកដង្ហើមបឺតចូលធាតុហ្វ័រម៉ាដេហៃដ៍ច្រើនយូរៗទៅ ស្ថិតក្នុងកំរិតនេះអាចប៉ះពាល់ដល់សុខភាពបាន ។
- កំរិតធាតុហ្វ័រម៉ាដេហៃដ៍ប្រហែលជាខ្ពស់ជាង នៅក្នុងផ្ទះសណ្ដោង និងផ្ទះចល័តដែលថ្មីជាង នៅពេលធាតុអាកាសក្ដៅ ។
- កំរិតធាតុហ្វ័រម៉ាដេហៃដ៍ មានខុសៗគ្នានៅក្នុងផ្ទះចល័ត ផ្ទះក្នុងឧទ្យាន និងផ្ទះសណ្ដោងចរ ប៉ុន្តែផ្ទះសណ្ដោង និងផ្ទះចល័តគ្រប់ប្រភេទទាំងអស់ដែលបានពិនិត្យសាក ខ្លះមានកំរិតខ្ពស់ ។

### តើអ្នកគួរតែធ្វើអ្វីខ្លះ?

- ប្រជាជនដែលរស់នៅក្នុងផ្ទះសណ្ដោង និងផ្ទះចល័ត គួរតែព្យាយាមផ្លាស់កន្លែង ទៅទីលំនៅជាអចិន្ត្រៃយ៍ នៅមុនពេលរដូវក្ដៅមកដល់ ។ គ្រួសារដែលរស់នៅក្នុងផ្ទះសណ្ដោងដែលមានកូន មនុស្សចាស់ ឬមនុស្សដែលមានជំងឺរ៉ាំរ៉ៃស្រាប់ហើយ ដូចជាជំងឺហឺត គួរតែបានផ្លាស់កន្លែងមុនគេ ។

CDC គឺជាភ្នាក់ងារខាងសុខភាពសាធារណៈនៃរដ្ឋបាលសហព័ន្ធ
នៅក្រោមក្រសួងសុខភាព និងសេវាមនុស្ស សហរដ្ឋអាមេរិក

- គ្រួសារដែលរស់នៅក្នុងផ្ទះសណ្តោងចរ និងផ្ទះចល័ត គួរតែចំណាយពេលនៅខាងក្រៅផ្ទះឲ្យបានច្រើន ដើម្បីយកខ្យល់បរិសុទ្ធឲ្យបានច្រើនជាទីបំផុត ។ នេះគឺជាសារៈសំខាន់ដ៏ពិសេស សំរាប់គ្រួសារដែលមានកូន មនុស្សចាស់ ឬមនុស្សដែលមានជំងឺរ៉ាំរ៉ៃ ដូចជាជំងឺហឺត ។
- ត្រូវបើកបង្អួចឲ្យបានច្រើនជាទីបំផុត ដើម្បីឲ្យខ្យល់បរិសុទ្ធចូលមក ។
- ត្រូវព្យាយាមរក្សាសីតុណ្ហភាពនៅខាងក្នុងផ្ទះសណ្តោងចរ និងផ្ទះចល័ត ឲ្យទាបបំផុតអាចនៅដោយកក់ក្តៅបាន ។
- ចូរកុំជក់បារី ហើយជាពិសេស ចូរកុំជក់បារីនៅក្នុងផ្ទះឲ្យសោះ ។
- បើសិនជាអ្នកខ្វល់ខ្វាយអំពីសុខភាព ត្រូវទៅជួបគ្រូពេទ្យ ឬអ្នកវិជ្ជាជីវៈខាងពេទ្យផ្សេងទៀត ។

## តើខ្ញុំអាចរកជំនួយនៅទីណា?

- អ្នកតំណាងនៃក្រសួងសុខាភិបាល និង FEMA នឹងមកមើលប្រជាជនដែលផ្ទះសណ្តោងរបស់គេបានពិនិត្យសាក ដើម្បីចែកចាយលទ្ធផលនៃការពិនិត្យសាកនិមួយៗរបស់គេ ។ ការមកមើលនេះនឹងចាប់ផ្តើមនៅថ្ងៃទី 21 ខែកុម្ភៈ ឆ្នាំ 2008 ។
- CDC នឹងធ្វើការប្រជុំជំរាបសាធារជន នៅក្នុងសហគមន៍ជាច្រើន នៅក្នុង Louisiana ក្នុងកំឡុងអាទិត្យនៃថ្ងៃទី 25 ខែកុម្ភៈ ឆ្នាំ 2008 ។ FEMA ក៏នឹងនៅឯអង្គប្រជុំដែរ ដើម្បីពិភាក្សាអំពីជំរើសទីលំនៅ ។
- CDC នឹងធ្វើការប្រជុំជំរាបសាធារជន នៅក្នុងសហគមន៍ជាច្រើន នៅក្នុង Mississippi ក្នុងកំឡុងអាទិត្យនៃថ្ងៃទី 3 ខែមីនា ឆ្នាំ 2008 ។ FEMA ក៏នឹងនៅឯអង្គប្រជុំដែរ ដើម្បីពិភាក្សាអំពីជំរើសទីលំនៅ ។

**សំរាប់ចំឡើយចំពោះសំណួរស្តីអំពីសុខភាព សូមទូរស័ព្ទទៅ**
**CDC 1-800-CDC-INFO (1-800-232-4636)**

**ដើម្បីឲ្យបានជ្រាបអំពីជំរើសទីលំនៅ សូមទូរស័ព្ទទៅ FEMA តាមលេខ**
**1-866-562-2381 ឬ TTY 1-800-462-7585**
**FEMA នឹងធ្វើការជាមួយអ្នក ដើម្បីផ្លាស់អ្នកទៅទីលំនៅផ្សេងៗទៀត ។**

CDC គឺជាភ្នាក់ងារខាងសុខភាពសាធារណៈនៃរដ្ឋបាលសហព័ន្ធ
នៅក្រោមក្រសួងសុខភាព និងសេវាមនុស្ស សហរដ្ឋអាមេរិក